# ព័ត៌មានស្តីពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
# សម្រាប់កុមារបរទេសដែលរស់នៅក្នុងប្រទេសកូរ៉េ( អាយុ ៥~១១ឆ្នាំ )

ចំនួនករណីដែលឆ្លងបានកើនឡើង ដោយសារប្រភេទសត្វលេចធ្លោនៃមេរោគបំប្លែងអូមីក្រុង និងចំនួនករណីដែលបានឆ្លងលើកុមារ (អាយុ ៥~១១ឆ្នាំ) ដែលកន្លងមកមិនបានរាប់បញ្ចូលក្នុងគោលដៅចាក់វ៉ាក់សាំង **ក៏កំពុងកើនឡើងយ៉ាងឆាប់រហ័សផងដែរ** ហើយ**ករណីធ្ងន់ធ្ងរ និងការស្លាប់ក៏កំពុងកើតឡើងផងដែរ។**

អាស្រ័យហេតុនេះ, **ព័ត៌មានទាក់ទងនឹងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់កុមារ(អាយុ៥~១១ឆ្នាំ)មានដូចខាងក្រោម។**

## ■ គោលដៅចាក់វ៉ាក់សាំង

○ ករណីកុមារដែលមានអាយុពី៥~១១ឆ្នាំ ជា**កុមារដែលមានហានិភ័យខ្ពស់**នឹងជំងឺប្រចាំកាយ គឺ**ត្រូវបានណែនាំឱ្យចាក់វ៉ាក់សាំងយ៉ាងសកម្ម** ដើម្បី**ការពារការឆ្លងជំងឺកូវីដ-១៩ធ្ងន់ធ្ងរ។**

○ **ករណីដែលកុមារមានសុខភាពល្អ** សូមណែនាំឱ្យ**ចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត** បន្ទាប់ពីពិនិត្យយ៉ាងហ្មត់ចត់ អំពី**អត្ថប្រយោជន៍នៃការចាក់ថ្នាំបង្ការ** និងការឆ្លងជំងឺកូវីដ-១៩ និង**ហានិភ័យដែលទាក់ទងនឹងប្រតិកម្មមិនល្អ** បន្ទាប់ពីចាក់វ៉ាក់សាំង។

※ ករណីមានប្រវត្តិនៃការឆ្លងជំងឺកូវីដ គឺមិនត្រូវបានណែនាំឱ្យចាក់វ៉ាក់សាំងទេ និងករណីមានការឆ្លងជំងឺកូវីដ បន្ទាប់ពីចាក់វ៉ាក់សាំងលើកទី១ ក៏មិនត្រូវបានណែនាំឱ្យចាក់វ៉ាក់សាំងលើកទី២ផងដែរ

## ■ ប្រភេទវ៉ាក់សាំង និងរយៈពេលចាក់

○ វ៉ាក់សាំងចាក់ឱ្យកុមារ ហ្វាយសឺរ ( មានកម្រិត១/៣ រួមបញ្ចូលប្រសិទ្ធភាពធាតុផ្សំ នៃវ៉ាក់សាំងមនុស្សពេញវ័យ )

○ ករណីកុមារ ចាក់ដូសលើកទី២ គឺ**ចាក់បាននៅចន្លោះពេល ៨សប្តាហ៍ (៥៦ថ្ងៃ)** បន្ទាប់ពីការចាក់វ៉ាក់សាំងលើកទី១។

* ករណីត្រូវការចាក់វ៉ាក់សាំងដូសលើកទី២ មុនកាលកំណត់ដោយសារហេតុផលវេជ្ជសាស្ត្រឬស្ថានភាពផ្ទាល់ខ្លួន គឺអាចចាក់វ៉ាក់សាំងក្នុងរយៈពេល ៣សប្តាហ៍(២១ថ្ងៃ) ចន្លោះពេលដែលត្រូវបានអនុម័តដោយក្រសួងសុវត្ថិភាពចំណីអាហារ និងឱសថ។

## ■ វិធីសាស្ត្រ និងកាលវិភាគនៃការកក់ទុក

▷ ការកក់ទុកជាមុន គឺចាប់ពី(ព្រហស្បតិ៍)ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២។

**1. ជនដែលបានចុះឈ្មោះជាជនបរទេស**

① ការកក់តាមរយៈអនឡាញ: ចូលប្រើប្រព័ន្ធកក់ទុកមុននៃការចាក់វ៉ាក់សាំងកូវីដ១៩(https://ncvr.kdca.go.kr) ហើយអាណាព្យាបាលកក់ជំនួស

② ការកក់ទុកតាមទូរស័ព្ទ: អាណាព្យាបាលកក់ជំនួស តាមរយៈមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ (☏១៣៣៩) ឬ រដ្ឋាភិបាលក្នុងតំបន់

③ ការចាក់ដោយមិនកក់ទុកមុន: ចាក់ភ្លាមៗនៅថ្ងៃដែលចង់ចាក់ បន្ទាប់ពីការចុះឈ្មោះក្នុងបញ្ជីបឋមនៃស្ថាប័នវេជ្ជសាស្ត្រ (បញ្ជាក់ដោយខ្សែទូរស័ព្ទ)

**2. ជនដែលមិនបានចុះឈ្មោះជាជនបរទេស(រួមទាំងជនបរទេសខុសច្បាប់):** បន្ទាប់ពីទទួលបានលេខគ្រប់គ្រងបណ្តោះអាសន្ន ពីមណ្ឌលសុខភាព អ្នកអាចធ្វើការកក់ទុកតាមទូរស័ព្ទ ឬទៅកក់ផ្ទាល់នៅស្ថាប័នសម្រាប់ចាក់វ៉ាក់សាំង(ស្ថាប័នវេជ្ជសាស្ត្រ ឬមណ្ឌលសុខភាព)

* នៅពេលចេញលេខគ្រប់គ្រងបណ្តោះអាសន្ន មិនត្រូវបានទាមទារឱ្យបង្ហាញអត្តសញ្ញាណ ដូចជា លិខិតឆ្លងដែន, ប័ណ្ណចុះឈ្មោះជនបរទេសទេ។

## ■ កាលវិភាគ និង ទីតាំងចាក់វ៉ាក់សាំង

▷ ការចាក់វ៉ាក់សាំង គឺអនុវត្ត ចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ថ្ងៃព្រហស្បតិ៍)។

○ស្ថាប័នដែលត្រូវបានចាត់តាំងសម្រាប់ការចាក់វ៉ាក់សាំងកុមារ មានចំនួន ១,២០០កន្លែង និងចាប់ពីថ្ងៃទី១៤ ខែមីនា(ថ្ងៃច័ន្ទ) អ្នកអាចចូលពិនិត្យមើល នៅលើគេហទំព័រចាក់វ៉ាក់សាំងកូវីដ១៩(ncv.kdca.go.kr)បាន។

※ អ្នកអាចពិនិត្យមើលស្តង់ដារនៃការអនុវត្ត គោលការណ៍ណែនាំ, សម្ភារៈអប់រំ, ស្ថាប័នវេជ្ជសាស្ត្រ នៅក្នុងម៉ឺនុយ <**알림·서식**> → <**지침**>

| |
|---|
| ករណីជាកុមារ ចាំបាច់ត្រូវអមដំណើរជាមួយអាណាព្យាបាលឬអ្នកតំណាងផ្លូវច្បាប់ ដើម្បីសុវត្ថិភាពនៃការចាក់វ៉ាក់សាំង និងតាមដានប្រតិកម្មមិនល្អ។ (អាណាព្យាបាល គឺទៅជាមួយកុមារ បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណរួច បំពេញទម្រង់បែបបទរោគវិនិច្ឆ័យជាមុន នៅស្ថាប័នផ្តល់ថ្នាំបង្ការ) |

※ **សេចក្តីយោង**

– **ព័ត៌មានដែលពាក់ព័ន្ធនឹងអត្តសញ្ញាណ គឺត្រូវបានប្រើសម្រាប់គោលបំណងចាក់វ៉ាក់សាំងតែប៉ុណ្ណោះនិងយោងតាមប្រព័ន្ធលើកលែងកាតព្វកិច្ចជូនដំណឹងគឺនឹងមិនត្រូវបានជូនដំណឹងអំពីស្នាក់នៅដោយខុសច្បាប់ផ្សេងៗទៅការិយាល័យអន្តោប្រវេសន៍·ជនបរទេសទេ។**

- សម្រាប់ព័ត៌មានបន្ថែម សូមមើលនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ(KCDC) សម្រាប់ការចាក់វ៉ាក់សាំងកូវីដ១៩(https://ncv.kdca.go.kr)។